# រឿង មហាចោរនៅទល់ដែន

## ភាគទី១៩

ដើងសេះមួយលាន់ឮរំពង ឯវាលស្រែ។ សូរជើងសេះនេះកាន់តែមកជិតដល់។ នាងទេវី ព្រឺព្រួចក្នុងក្នុងចិត្ត។ កាមាមើលតាមបង្អួចទៅឃើញប្រាកដជាបងរបស់ខ្លួន គឺមានន្ទនោះឯង។

- ឥឡូវនៅស្ងៀមឈប់និយាយ។

នាងទេវីក៏ប្រុងស្មារតី ដៃទាំងពីរសំពះឱនមុខលុតជង្គង់ ។ ធីតាឮសូរជើងសេះដែលធ្វើឲ្យនាងព្រឺអស់ទាំងខ្លួន។ នាងភ័យផងអរផង។ នាងនឹកឆ្ងល់ថា អាកាមានេះវាឲ្យនាងធ្វើដូច្នោះតើមានប្រយោជន៍អ្វី? នាងបំបែរដៃនាងដែលសំពះឲ្យចំមាត់ទ្វារ ព្រោះកែវរលក្ខណ៍ដឹងថាគឺតាមច្រកទ្វារនោះហើយដែលប្ដីនាងបម្រុងនឹងចូលមក។ មានន្ទមកដល់មុខខ្ទម លោតចុះពីលើខ្នងសេះយ៉ាងរហ័ស។ អ្នករត់តម្រង់ទៅមាត់ទ្វារខ្ទម។ លុះទៅដល់មាត់ទ្វារអ្នកទុចង៉ក់មើលឃើញកាមានៅឈរច្រត់កែងដៃនឹងបង្អួច ឃើញនាងទេវីសំពះអ្នកយ៉ាងស្មោះស្ម័គ្រ។

- កាមា រឿងអី?

កាមាសើចនិយាយយ៉ាងស្លូតថា៖

- ខ្ញុំសូមជូនបងស្រីដែលបងបានផ្ញើខ្ញុំ ថែរក្សានោះមកបងវិញ។

មានន្ទនៅស្ងៀមស្ដាប់កាមា រួចនិយាយថា៖

- ម្ដេចក៏ឯងនិយាយសើចហាក់ខ្លើមរអើមម៉្លេះ?
- ហាស់ ៗ ពីព្រោះជារឿងដែលខ្ញុំពុំគួរនឹងជម្រាបបងសោះ។

មានន្ទខាំធ្មេញក្រឹត។

- រឿងអីកាមា? កាមាប្រាប់មកឲ្យឆាប់!
- កាមាដើរធ្វើពាយមាយនៅជិតបង្អួចនោះ

អត្ថបទដោយ៖ មាស សុភាព

- អើ ! សមណាស់ហើយ ប្រពន្ធបងនោះ ។ សមមុខបងឯងណាស់ហើយ ។ កាលបងផ្ដាំផ្ញើខ្ញុំ ៗ នឹកស្មានថាជាស្រីមួយល្អគួរគោរព ។ តែដល់ចុងបង្អើយ ហ៊ី ! ខ្ញុំមិនចង់និយាយទៀតទេ។

មាន្ទនស្ទុះទៅចាប់កាមា ញេញញញ្ញ មុខឡើងក្រហម។ ទេវីរលត់អស់ស្មារតី។

- កាមានិយាយ តោងនិយាយប្រាប់បងឲ្យឆាប់មក!
- រឿងនេះក្រែងបងខឹងជ្រុលណា!
- រឿងអ្វី ? កាមារឿងអ្វី ? យី ! កាមាតោងនិយាយមក។
- ដោយបងតឿនឲ្យខ្ញុំនិយាយហើយ ខ្ញុំក៏និយាយទៅចុះ ប្រពន្ធបង ខ្ញុំបានបណ្ដេញចេញពីភូមិយើង។ ខ្ញុំសូមទោសបងទៅចុះ។ តែបានជាបណ្ដេញនេះ ពីព្រោះទេវីជាស្រីមួយយ៉ាងអាក្រក់បំផុត នាងលួចមានសហាយ។
- យី ! អីទេវីមានសហាយ ? ទេវីក្បត់អញ ?
- បាទ !
- សហាយនឹងអ្នកណា ? អាណាមួយហ៊ានសហាយជាមួយប្រពន្ធអញ ? ប្រាប់មក។ អូនប្រាប់បងមក។
- បើបងដឹងបងធ្វើអាសហាយនោះយ៉ាងណាទៅ ?
- ហ៊ឺស កាមាអូន ! ដាវៗ កាត់ហុតឈាម!
- ហ៊ីៗ សហាយវានេះមិននៅឆ្ងាយទេ គឺនៅជិតៗនេះ។ គឺជាមនុស្សម្នាក់ខែងសម្ដីលើក ឫកពាខ្លង់ខ្លស់ បុណ្យស័ក្តិធំ ប៉ុន្ដែបងទៅចង់ពៀរនឹងអាសហាយនោះបានជាការអ្វី ? ស្រីវាខូចទេតើ ?
- អញផ្ដាន្ទាទោសទាំងពីរហ្នឹង ។ កាមា ! អញឲ្យឯងជួយរក្សា ឯងគ្មានបានការអីទេ។
- ខ្ញុំមើលអស់ប៉ុណ្ណឹងហើយ!
- កាមា អាណាមួយមានបណ្ដាសក្តិធំ ហ៎ ? តើអាណាមួយ . . . បងចង់ស៊ីសាច់ហុតឈាមវាឥឡូវ កាមាប្រាប់មងមក វានៅជិតៗនេះរឺ ?

អត្ថបទដោយ៖ មាស សុភាព

កាមាសើច និយាយមួយៗថា៖

- មនុស្សអប្រិយកំណាចចិត្តទាបអាម៉ាស់នោះ គឺ . . . គឺ . . . គឺ . . . ខ្ញុំ ។
- ប្អូនឯង ? យី ! អីប្អូនឯងសហាយនឹងប្រពន្ធបង ?
- បាទ គឺខ្ញុំនេះឯង !
- យី ! កាមា ! ប្អូនសំលាញ់ . . . នែ! ម្តេចទេវីអូន ! ម្តេចអូនធ្វើដូច្នោះ? ទេវីអូន ! បងស្រលាញ់អូនប្តូរជីវិតគ្មានតក់ គ្មានណាយ គ្មានភ្លេចមួយពេល។ បងអាណិត ប្អូនពល់វេលា។ ទេវីអូន ! បងស្រលាញ់ហៅពេញបង់ចិត្ត អូនក្បត់ចិត្តបង។ បើអូនទៅស្រលាញ់អ្នកណា ក្រៅពីប្អូនរបស់បង ៗមិនថាអ្វីទេ នេះប្អូនស្រលាញ់ប្អូនប្រុសរបស់បង។ ក្តៅណាស់ ក្រហាយណាស់ ឈឺណាស់ ! ទេវី ! ទេវីអូន ! ហេតុម្តេចយ៉ាងហ្នឹង ? អូននិយាយមកមើល ប្រាប់មក ពន្យល់មក។
- មើលហ្ន៎ ! សត្វនេះវានៅស្ងៀមឈឹង ។
- ទេវី ៗ !យើងព្រាត់គ្នាពីពេលនេះហើយ។

មែន ! នាងទេវីព្រាត់មែន ព្រាត់ព្រោះនាងនិយាយពុំរួច កម្រើកខ្លួនពុំបាន។ ជីតាមានតែទឹកភ្នែកដែលហូរប៉ុណ្ណោះ ។ ដៃនាងឡើងញ័រ ចិត្តនាងតឹងៗដាងជាប់ចំណងប្រាំប្រការទៅទៀត ។ ពាក្យរបស់កាមាមួយម៉ាត់មានពាក្យថា នាងបានសហាយនឹងវា ធ្វើឲ្យចិត្តនាងធ្លាក់ក្តុកយ៉ាងខ្លាំង។ ពាក្យនេះចាក់ដោតដួងចិត្តនាងយ៉ាងរកាំបំផុត រួចមុតដូចកាំបិតដែលចាំងរំលំព្រឹក្សានៃសេចក្តីសុខរបស់ស្រី។ ឱ ! ប្តីនាងពុំដឹងរឿងនឹកស្មានថាការនេះជាការពិត។ មានន្ទបែរទៅនិយាយជាមួយកាមាថា

- ថ្ងៃបែរគងភ្នំ ប្អូនឯងទៅជួបនឹងបងនៅក្រោមដើមពោធិ៍កុំខាន។

កាមាសើចក្អាកក្អាយងក់ក្បាលតបវិញ៖

- បាទបង ! ថ្ងៃបែរគងភ្នំជួបគ្នាក្រោមដើមពោធិ៍។

អត្ថបទដោយ៖ មាស សុភាព

រួចមានទ្ធបែរមកមើលនាងទេវីជាចុងក្រោយបង្អស់។ អ្នកមួម៉ៅក្តៅក្រហាយក្នុងចិត្តជាពន់ពេក។ ពីដើមរូបនាងទេវីជាទីត្រជាក់ចិត្ត ឥឡូវរូបដដែលនេះក្លាយទៅជាភ្លើងទៅវិញ។ អ្នកខឹងយ៉ាងខ្លាំង រហូតដល់លែងមើលមុខនាងទៀត អ្នកនិយាយជាទីបង្ហើយថា៖

- ទេវី ស្រីកាលកាឡកណ្ណីឫស្យា អញលែងបានឃើញឯងទៀតហើយ។

ថាដូច្នោះស្រេច មានទ្ធស្ទុះចេញពីផ្ទះ រត់ឡើងលើខ្នងសេះទៅ។ ព្រលឹងនាងទេវីស្ទុះតាមបណ្តាលឲ្យរូបនាងដួលដេកស្តូកលើក្តារ។ លើខ្នងសេះ មានទ្ធឈឺចាប់ក្នុងចិត្តជាពន់ពេក។ ភ្នែកលែងមើលអ្វីឃើញ ត្រចៀកលែងឮអ្វី នេះហើយដែលជាស្ថានភាពដែលអ្នករស់ក្នុងកេសារបស់អ្នកហាក់មានអ្វីវិលស្ទុង នាំឲ្យនឹកអ្វីពុំឃើញ គិតអ្វីក៏ពុំយល់ មានតែរឿងនាងទេវីកាឡកណ្ណីប៉ុណ្ណោះទេដែលមកបុកដើមទ្រូងអ្នក ញាំងៗ គ្មានត្រាប្រណី។ បុរសនឹកឃើញកាលគ្រាមុន អ្នកស្រលាញ់ស្រ្តីនេះយ៉ាងអស់ពីពោះ។ អ្នកបានប្តេជ្ញាថា រស់ស្លាប់ជាមួយទេវីតែមួយរហូតរៀងទៅ ដោយជឿថា ជីវិតអ្នកមុខជាបានរស់និត្យនៅជាមួយនាងមិនខាន។ ហើយស្មានទៀតថា នាងមុខជាធ្វើឲ្យអ្នក បានសប្បាយជានិច្ចវិញ។

មាណពប្រឹងត្រិះរិះរកឃើញថា កាលស្រលាញ់គ្នានោះ នាងនេះបាននិយាយនឹងអ្នក រួចកាលនិយាយគ្នានោះ នាងបានបង្ហាញឲ្យឃើញថា នាងស្មោះត្រង់មែនស្ទើរហ៊ានចាត់ទុកថាគ្មាននារីណាមួយមកប្រៀបបានឡើយ ពីព្រោះគ្រប់ពាក្យដែលនាងចេញស្តី នាងគ្មានបានគិតទេ ស្រីនិយាយរអិលរអិចទាក់។ រីឯពាក្យមួយម៉ាត់ៗ បុរសជាសង្សារសង្កេតឃើញទឹកចិត្តមែនៗ នៃសេចក្តីស្នេហា។ មកដល់មួយពេលនេះ ទេវីស្រីដាច់ចិត្តមានសហាយទៀត ភ្លេចអ្នកជាប្តី ភ្លេចអស់ពាក្យសម្តី ភ្លេចអស់អំពើដែលធ្វើទៅវិញទៅមកតាំង ពីអំពើតូចតាច បន្តិចបន្តួចរហូតដល់ទៅលូកដៃចោលខ្លួនទាំងស្រុងចូលក្នុងរង្វង់ដៃគ្នាទៅវិញទៅមក រហូតដល់រួមរស់ រួមមេត្រីនៃបនិត្យគ្នាជាប្តីប្រពន្ធ។ មានទ្ធនឹកឃើញសព្វគ្រប់ដូច្នោះ អ្នកអស់កម្លាំងចិត្តហេវនឹងរកជឿស្រីណាទៀតមិនបាន។ ក្នុងពេលនោះ អ្នកចាត់ស្រីទាំងអស់ជាភេទអប្បលក្ខណ៍ អាក្រក់រកគ្មាន។ ភេទមោហៈ នេះជាភេទស្រើបស្រាល នឹងកាមរាគ ចិត្តមិនធ្ងន់ មិនចេះអត់ មិនស្គាល់ខុសត្រូវ អាក្រក់ល្អ ស្រេកឃ្លាននឹងកាមគុណ ឃ្លាន ! ឃ្លាន ! . . . ណាស់ឃ្លានរហូតទៅក្បត់។ មានទ្ធខាំធ្មេញ ដោយហាក់មើលឃើញនាងទេវីធ្វើឫក ធ្វើពាររកកាមា

អត្ថបទដោយ៖ មាស សុភាព

ជាសហាយ។ កម្លោះហាក់ឃើញនាងញញឹមដោយឥតអៀនខ្មាស ដាក់ប្រុសថ្មី ហាក់ឃើញនាងបើកទ្វារឲ្យគេចូលមក ដោយស្ទុះទៅទទួលគេ ចោលខ្លួនទាំងស្រុង ទៅក្នុងកណ្ដាប់ដៃគេបណ្ដោយឲ្យគេឱបរឹតដូចកាលនាងបានធ្វើជាមួយអ្នកដែរ ។ ស្រីឫស្យានេះនិយាយរកគេដូចបាននិយាយនឹងអ្នកជាប្រាកដ។

មានន័ទ្ធនឹកទៀតថា បើអ្នកមកទាន់ក្នុងពេលនោះ អ្នកមុខជាហូតដាវវាត់ឲ្យដាច់ចង្កេះទាំងពីរនាក់ឲ្យស្លាប់ ជាមួយគ្នាមួយរំពេចមិនខាន ។ ក្រោយពីសុបិននេះ មានន័ទ្ធសន្មតថា ស្រីដែលមានរូបល្អជាស្រីមានចិត្តអាក្រក់ ។ រូបវាល្អណាស់ វាអាងរូប ចង់ឲ្យតែគេវាល់គ្នាស្រលាញ់វា។ ឱ ! ទេវី ! ស្រីទាំងអស់អាក្រក់គ្មានសល់មួយនាក់ ទោះមានរូបមិនល្អក៏ដោយ គឺថាណាមួយក៏ដូចណាមួយ។ អាស្រ័យហេតុនេះ មានន័ទ្ធនឹកដល់ព្រះពុទ្ធអង្គលោកបានហៅចំជាកំពូលមនុស្សមែន។ លោកយល់រឿងនេះ រួចបានលះបង់ទាំងអស់ដើម្បីព្រះនិព្វាន ដែលជាឋានផុតទុក្ខ។

ជិះលើខ្នងសេះមានន័ទ្ធវង្វេងអស់ស្មារតី។ នឹកម្ដងឃើញថាត្រូវសម្លាប់ស្រីៗឲ្យអស់។ នឹកម្ដងឃើញថា ត្រូវសម្លាប់ប្រុសៗដែលអាក្រក់ ទៅស្រលាញ់ប្រពន្ធគេឲ្យអស់បានត្រូវដាង។ នឹកតទៅទៀតឃើញថាទេ! កុំរវល់ នេះហើយជាជីវិត មានទុក្ខ មានសុខ មានក្បត់ មានស្រលាញ់ មានស្អប់ . . . ។ល។ សំរេចសេចក្ដី មានន័ទ្ធនៅតែមានទុក្ខដដែល។ វាលដែលអ្នកកំពុងជិះសេះកាត់ធំល្វឹងល្វើយ បីដូចវាលវដ្ដសង្សារដែលអ្នកកំពុងឆ្លងកាត់។ អ្នកឃើញថា អ្នកប្រឹងទៅមុខតែម្នាក់ឯងត្បិតគូស្នេហាគេចោលអ្នកហើយ។ វាលនេះមើលយូរបន្តិចទៅ ក្លាយទៅជាមហាសាគរមួយដ៏ធំក្រៃលែង ដែលរកមើលជើងមេឃពុំឃើញ ។ ខ្យល់ដែលបក់រវិចៗ ក្លាយទៅជាខ្យល់ព្យុះព្យោមាយ៉ាងខ្លាំងអនេក ។ សេះដែលអ្នកជិះក្លាយជាកូនទូកតូចមួយ ដែលឃ្វេងឃ្វាងៗ កណ្ដាលសមុទ្រ បោកបក់ដោយជំនោរខ្យល់។ តែកូនទូកនេះ គឺមានន័ទ្ធដែលភ័យប្រឹងតស៊ូនឹងខ្យល់ កុំឲ្យលិចទូកបាន។

(សូមរង់ចាំតាមដានភាគទី២០ នៅសប្ដាហ៍ក្រោយ)

អត្ថបទដោយ៖ មាស សុភាព